00940689



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 07 / 2013
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៣
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង
ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើសំណើរបស់ នួន ជា ស្នើសុំឲ្យទទួលយកភស្តុតាងថ្មី, ឲ្យចាប់ផ្តើមការស៊ើបអង្កេត និងឲ្យកោះហៅលោក ROB LEMKIN

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Jacques VERGÈS
Anta GUISSÉ

## ១. សេចក្តីផ្តើម

1. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ មេធាវីការពារក្តី នួន ជា បានប្រកាសថា ខ្លួនបានទទួល "ព័ត៌មានថ្មីពិសេស" នៅនាទីចុងក្រោយនៃសវនាការមុនថ្ងៃនោះមួយថ្ងៃ ដែលពួកគាត់យល់ថាវាជាព័ត៌មានដែល "មានការជាប់ពាក់ព័ន្ធយ៉ាងសំខាន់ទៅនឹងសវនាការនេះ"[1]។ មេធាវីការពារក្តីបានបញ្ជាក់ថា ខ្លួនបានទទួលអ៊ីម៉ែលមួយពីលោក Rob LEMKIN ដែលជាសហផលិតករខ្សែភាពយន្តមានចំណងជើងថា *សត្រូវប្រជាជន* (*Enemies of the People*) និង *មួយថ្ងៃនៅពោធិ៍ជ្រៃ* ( *One Day at Po Chrey)* ដែលមានព័ត៌មានដោះបន្ទុក ("អ៊ីម៉ែល")។ មេធាវីការពារក្តីបានស្នើសុំឱ្យផ្អាកសក្ខីកម្មរបស់លោក Heder ពីព្រោះគាត់បានសម្ភាសកម្មាភិបាលនានាមកពីភូមិភាគពាយ័ព្យ ហើយទំនងជានឹងផ្តល់សក្ខីកម្មទាក់ទងនឹងអង្គហេតុដូចគ្នាទៅនឹងលោក LEMKIN[2]។ អង្គជំនុំជម្រះបានសម្រេចមិនផ្អាកសក្ខីកម្មរបស់លោក Heder ឡើយ ហើយបានស្នើឱ្យមេធាវីការពារក្តី នួន ជា ដាក់សារណាជាលាយលក្ខណ៍អក្សរ ពាក់ព័ន្ធនឹងផ្នែកដែលនៅសល់នៃសំណើរបស់ខ្លួន[3]។ ឥឡូវនេះ អង្គជំនុំជម្រះបានទទួលសំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកភស្តុតាងថ្មី, ឱ្យកោះហៅលោក Rob LEMKIN និងឱ្យចាប់ផ្តើមការស៊ើបអង្កេត ("សំណើ")[4]។ តាមការបង្គាប់របស់អង្គជំនុំជម្រះ ភាគីផ្សេងៗទៀតបានឆ្លើយតបទៅនឹងសំណើដោយផ្ទាល់មាត់នៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣។

## ២. សារណា

2. មេធាវីការពារក្តីបានស្នើឱ្យអង្គជំនុំជម្រះទទួលយកអ៊ីម៉ែល ដោយសម្អាងលើហេតុផលថា វាជាភស្តុតាងដោះបន្ទុក និងពាក់ព័ន្ធទៅនឹងការសម្លាប់មន្ត្រីរដ្ឋការរបស់ លន់ នល់ នៅក្រោយថ្ងៃទី ១៧ ខែ

---

[1] ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/221.1 ទំព័រ ២ ដោយសារតែបញ្ហាដែលត្រូវបានលើកឡើងមានលក្ខណៈមិនច្បាស់លាស់ អង្គជំនុំជម្រះបានចាប់ផ្តើមពិភាក្សាជាសម្ងាត់។ នៅពេលដែលអង្គជំនុំជម្រះយល់ច្បាស់ថាបញ្ហានោះជាប់ពាក់ព័ន្ធនឹងអ៊ីម៉ែលដែលបានលើកឡើងនោះ អង្គជំនុំជម្រះបានចាប់ផ្តើមពិភាក្សាជាសាធារណៈវិញ និងបានស្នើឱ្យ លោក Koppe បញ្ជាក់ឡើងវិញនូវសារណារបស់គាត់នៅក្នុងតុលាការជាសាធារណៈ។ ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/221.1 ទំព័រ ៤-៥។ អង្គជំនុំជម្រះបានបង្គាប់ឱ្យដាក់ប្រតិចារឹកទាំងមូលជាឯកសារសាធារណៈ។

[2] ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/221.1 ទំព័រ ៤, ១១។

[3] ប្រតិចារឹក ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/221.1 ទំព័រ ១៧-១៨។

[4] សំណើសុំទទួលយកភស្តុតាងថ្មី កោះហៅ ROB LEMKIN និងចាប់ផ្តើមការស៊ើបអង្កេត ឯកសារ E294 ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៣។

មេសា ឆ្នាំ ១៩៧៥[5]។ មេធាវីការពារក្តីបញ្ជាក់ថា ខ្សែភាពយន្តដែលផលិតរួមគ្នាដោយលោក LEMKIN មាននៅក្នុងសំណុំរឿងរួចហើយនោះ ត្រូវបានកាត់ចេញពីវីដេអូ និងខ្សែអាត់សម្លេងរយៈពេល១០ឆ្នាំ ដែលសម្ភាសជាមួយ នួន ជា[6] ហើយថា "គ្មានអង្គហេតុដោះបន្ទុកណាមួយដែលបានរៀបរាប់នៅក្នុងអ៊ីម៉ែលនេះ អាចរកបាននៅក្នុងសម្រង់អត្ថបទដែលមានក្នុងសំណុំរឿងនោះទេ"[7]។ មេធាវីការពារក្តីក៏បានអះអាងផងដែរថា លោក LEMKIN មានវត្តមានយ៉ាងហោចណាស់ម្តងនៅពេលសម្ភាស នួន ជា[8]។ ដូច្នេះ មេធាវីការពារក្តីអះអាងថា ប្រាកដណាស់លោក LEMKIN "ដឹងយ៉ាងច្បាស់អំពីកិច្ចសម្ភាសន៍ទាំងនោះ និងបានដឹងច្បាស់អំពីការប្រើប្រាស់កិច្ចសម្ភាសន៍ទាំងនោះដើម្បីបង្កើតជាបទពណ៌នា ដូចមានបង្ហាញ នៅក្នុងខ្សែភាពយន្ត *សត្រូវប្រជាជន* និងក្រោយមកត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនេះ"[9]។ លើសពីនេះទៀត មេធាវីការពារក្តីអះអាងថា បញ្ហាចំពោះភាពអាចជឿជាក់អំពីអំណោះអំណាងរបស់លោក LEMKIN អាចពាក់ព័ន្ធជាមួយនឹងតម្លៃជាភ័ស្តុតាង ប៉ុន្តែមិនពាក់ព័ន្ធនឹងការទទួលយកនោះទេ[10]។

3. មេធាវីការពារក្តី នួន ជា ស្នើបន្ថែមទៀតឱ្យកោះហៅលោក LEMKIN ដើម្បីមកផ្តល់សក្ខីកម្ម ចំពោះចម្លើយពាក់ព័ន្ធនឹងការប្រព្រឹត្តទៅលើសមាជិកកំពូលៗនៃរដ្ឋាភិបាល លន់ នល់ និងការរកឃើញរបស់គាត់ដែលមានលក្ខណៈដោះបន្ទុក ទាក់ទងនឹងការទទួលខុសត្រូវរបស់ នួន ជា ចំពោះការសម្លាប់នៅទួលពោធិ៍ជ្រៃ[11]។ មេធាវីការពារក្តីអះអាងថា គាត់គួរតែផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ ទាក់ទងនឹងទួលពោធិ៍ជ្រៃ ឬក៏ក្នុងនាមជាសាក្សីអង្គហេតុ ដើម្បីពិពណ៌នាអំពីភ័ស្តុតាងដែលគាត់បានប្រមូល និងអំពីសាក្សីនានាដែលគាត់បានសម្ភាស[12]។

4. ចុងក្រោយ មេធាវីការពារក្តី នួន ជា បានស្នើឱ្យចាប់ផ្តើមកិច្ចស៊ើបសួរ ដោយស្នើឱ្យទាក់ទងទៅលោក LEMKIN និងស៊ើបអង្កេតទៅលើភ័ស្តុតាងដែលថា ទួលពោធិ៍ជ្រៃ "គឺជាកន្លែងសម្លាប់ រង្គាលក្រោមបញ្ជារបស់ រស់ ញឹម ពុំមែនក្រោមបញ្ជារបស់មជ្ឈិមបក្សឡើយ[13]។ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំ

---

[5] សំណើរដែល កថាខណ្ឌ ៤។

[6] សំណើរដែល កថាខណ្ឌ ៥។

[7] សំណើរដែល កថាខណ្ឌ ៥។

[8] សំណើរដែល កថាខណ្ឌ ៦។

[9] សំណើរដែល កថាខណ្ឌ ៧។

[10] សំណើរដែល កថាខណ្ឌ ៨។

[11] សំណើរដែល កថាខណ្ឌ ១៣។

[12] សំណើរដែល កថាខណ្ឌ ១៣។

[13] សំណើរដែល កថាខណ្ឌ ១២។

ជម្រះទទួលយកនូវសំណៅនានានៃឯកសារភ័ស្តុតាងដែលលោក LEMKIN មាន និងស្នើឡើងថា ផ្នែកបឋមនៃកិច្ចសួរសួរ អាចបញ្ចប់តែនៅក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ[14]។

5. មេធាវីការពារក្តី ខៀវ សំផន គាំទ្រមេធាវីការពារក្តី នួន ជា និងស្នើឱ្យកោះហៅនាយក និង ផលិតករមកផ្តល់សក្ខីកម្ម។ មេធាវីការពារក្តីលើកឡើងថា អ៊ីម៉ែលនេះគឺជាភ័ស្តុតាងដោះបន្ទុកថ្មី ដែលពាក់ព័ន្ធនឹងជនជាប់ចោទទាំងពីរ ដោយសារតែពួកគាត់ត្រូវបានចោទប្រកាន់ជាផ្នែកនៃ សហឧក្រិដ្ឋកម្មរួម។ មេធាវីការពារក្តីអះអាងថា ភ័ស្តុតាងជាឯកសារនេះ មិនអាចត្រូវបានយល់ឡើយ ប្រសិនបើមិនស្ថិតក្នុងបរិបទដ៏ត្រឹមត្រូវ ដូច្នេះហើយតម្រូវឱ្យមានការសាកសួរលោក LEMKIN សម្រាប់ការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះ[15]។

6. សហព្រះរាជអាជ្ញាជំទាស់ទៅនឹងសំណើសុំដាក់អ៊ីម៉ែលនេះទៅក្នុងសំណុំរឿង ក៏ដូចជាចំពោះសំណើសុំកោះហៅលោក LEMKIN ប៉ុន្តែសហព្រះរាជអាជ្ញាគាំទ្រឱ្យមានកិច្ចសួរសួរមួយដែលមានកម្រិត។ សហព្រះរាជអាជ្ញាអះអាងថា លោក LEMKIN គឺជាផលិតករខ្សែភាពយន្ត មិនមែនជាអ្នកជំនាញផ្នែកខ្មែរក្រហម ឬផ្នែករចនាសម្ព័ន្ធរដ្ឋបាលបក្សកុម្មុយនីស្តកម្ពុជាទេ ហើយថា គាត់មិនគួរឱ្យជឿជាក់បានឡើយ ដោយសារមានការបង្ហាញឱ្យឃើញតាមរយៈការចងចាំមិនត្រឹមត្រូវរបស់គាត់អំពីខ្លឹមសារនៃ DVD[16]។ មូលហេតុរបស់លោក LEMKIN ក៏គួរឱ្យសង្ស័យផងដែរ ដោយសារគាត់ជំទាស់ទៅនឹងដំណើរការសួរដេញដោលនៃសវនាការនេះ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអះអាងថា ដោយសារតែលោក LEMKIN មិនមានវត្តមានក្នុងអំឡុងពេលការធ្វើសម្ភាសន៍សំខាន់ៗបំផុតនោះ ហើយថាដោយសារតែលោក ថេត សម្បត្តិ ដែលបានធ្វើការស្រាវជ្រាវ និងបានសម្ភាសបុគ្គលនានានៅក្នុងវីដេអូអំពីពោធិ៍ជ្រៃនោះ ដូច្នេះលោក LEMKIN ពុំមានជំនាញ ឬចំណេះដឹងដែលធ្វើឱ្យគាត់គួរត្រូវបានកោះហៅមកធ្វើជាសាក្សី ឬជាអ្នកជំនាញឡើយ។ លើសពីនេះទៀត សហព្រះរាជអាជ្ញាជំទាស់ទៅនឹងការដាក់បញ្ចូលអ៊ីម៉ែលនោះ ពីព្រោះវាមិនត្រឹមត្រូវក្នុងការបញ្ជាក់អង្គហេតុទាំងនេះឡើយ ដែលវាជាការបកស្រាយសំដីរបស់ នួន ជា ដែលមិនគួរឱ្យជឿជាក់បាននោះ។ សហព្រះរាជអាជ្ញា

---

[14] សំណើដដែល កថាខណ្ឌ ១២។

[15] ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/223.1 ទំព័រ ៧៦-៧៧។

[16] អ៊ីម៉ែលនោះសរសេរថា "គាត់ [នួន ជា] មិនយល់ស្របឡើយថា មន្ត្រីកំពូលរបស់ លន់ នល់ ត្រូវបានគេសម្លាប់នោះទេ។ អ្វីដែលគាត់បាននិយាយនោះគឺថា មន្ត្រីកំពូលៗ និងសមាជិកគណៈរដ្ឋមន្ត្រី របស់ លន់ នល់ ចំនួនប្រមាណ៦រូប ត្រូវបាន ដាក់ឱ្យស្ថិតនៅក្រោមដំណើរការនីតិវិធីដ៏ត្រឹមត្រូវរបស់បដិវត្តន៍ និងត្រូវបានផ្តន្ទាទោសប្រហារជីវិតដោយតុលាការយោធា នេះបើតាមការចងចាំ ហើយ នួន ជា មិនបានចូលរួមក្នុងការសម្រេចទេ"។ នៅក្នុង DVD ក.ស.ព អះអាងថា នួន ជា បានបញ្ជាក់ថា "ពួកគេ [មេដឹកនាំបួន ឬប្រាំនាក់នៃរបបមុន] ត្រូវតែកម្ទេចចោល ពួកគេសមនឹងទទួលនូវទោសទណ្ឌយ៉ាងធ្ងន់ធ្ងរបំផុត ពួកគេបានក្បត់ប្រទេសជាតិ ចូលដៃជាមួយពួកបរទេស" ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/223.1 ទំព័រ ៧៩-៨០។

អះអាងថា វាជាការមិនត្រឹមត្រូវទេក្នុងការទទួលយកអ៊ីម៉ែលមួយតាមពាក្យចចាមអារ៉ាម ហើយដែលបុគ្គលដដែលនេះ ពុំមានបំណងផ្តល់នូវសម្ភារដើមនោះ[17]។

7. ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាពុំបានជំទាស់ទៅនឹងសំណើសុំផ្តល់ព័ត៌មាន ដែលត្រូវបញ្ជូនទៅលោក LEMKIN និងលោក សម្បត្តិ នោះឡើយ ដរាបណាសំណើនោះត្រូវ បានកម្រិតយ៉ាងតឹងរ៉ឹងត្រឹមការផ្តល់នូវសម្ភារដែលពួកគាត់មានប៉ុណ្ណោះ រួមទាំង ឈុតវីដេអូ និងខ្សែអាត់សំឡេង និងឯកសារសំណេរទាំងអស់ ដែលជាមូលដ្ឋានក្នុងការសរសេរសៀវភៅដែលមានចំណងជើងថា "*នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះ ម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់*" (Behind the killing fields: a Khmer Rouge leader and one of his victims)[18]។ បន្ទាប់មក សម្ភារនេះអាចត្រូវបានផ្តល់ទៅឱ្យភាគីនានាដោយសម្ងាត់ ហើយភាគីទាំងនោះត្រូវបានស្នើឱ្យធ្វើសារណាទាក់ទងនឹងភាពអាចទទួលយកបាននៃសម្ភារនេះ។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា សំណើសុំព័ត៌មាននេះ ប្រហែលជានឹងត្រូវបានគេនៅស្ងៀមមិនឆ្លើយតប ឬរងនូវការបដិសេធ[19]។

8. ដើមបណ្តឹងរដ្ឋប្បវេណីជំទាស់ទៅនឹងសំណើនេះ។ ពួកគាត់អះអាងថា លោក LEMKIN មិនមែនជាអ្នកជំនាញឡើយ ហើយថា ភាគច្រើននៃអ្វីៗដែលគាត់បាននិយាយ មិនអាចទទួលយកជាភស្តុតាងបានឡើយ។ ពួកគាត់អះអាងទៀតថា ប្រសិនបើសំណើបឋមទាក់ទងនឹងអ៊ីម៉ែល មិនអាចទទួលយកបាននោះ សំណើសុំកោះហៅលោក LEMKIN ឬសំណើសុំឱ្យមានកិច្ចស៊ើបសួរក៏មិនអាចទទួលយកបានដែរ។ អ៊ីម៉ែលនោះពុំមានភាពជាប់ពាក់ព័ន្ធ និងមិនបញ្ជាក់នូវអ្វីដែលជាគោលដៅនៃការស្នើសុំបញ្ជាក់ឡើយ ដោយសារការបង្ហាញឱ្យឃើញនូវភាពមិនច្បាស់លាស់នៃអ៊ីម៉ែលនោះ។ ប្រសិនបើ នួន ជា ខ្លួនគាត់ផ្ទាល់ជឿជាក់ថា សម្រង់វីដេអូនោះ មិនតំណាងឱ្យនូវអ្វីដែលគាត់ពិតជាបាននិយាយនោះ វាជាប្រការមួយគួរឱ្យភ្ញាក់ផ្អើលដែលគាត់មិនបានបញ្ជាក់ឱ្យច្បាស់លើចំណុចនេះកាលពីមុន[20]។

9. មេធាវីការពារក្តី នួន ជា ឆ្លើយតបថា លោក LEMKIN មិនបានដាក់ខ្លួនគាត់ជាអ្នកជំនាញទេ។ គាត់គ្រាន់តែចង់ជម្រាបជូនមេធាវីការពារក្តីថា អ្វីដែលបានរាយការណ៍នៅក្នុងកាសែតក្នុងស្រុកនោះ មិនស៊ីសង្វាក់គ្នាជាមួយនឹងការយល់ដឹងផ្ទាល់របស់គាត់ឡើយ។ សម្រង់ខ្សែវីដេអូនេះ ត្រូវបានចាក់បញ្ចាំង

---

[17] ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/223.1 ទំព័រ ៧៨-៨០។

[18] "*នៅពីក្រោយវាលពិឃាត៖ មេដឹកនាំខ្មែរក្រហមម្នាក់ និងជនរងគ្រោះ ម្នាក់ក្នុងចំណោមជនរងគ្រោះជាច្រើនរបស់គាត់*" "Behind the killing fields: a Khmer Rouge leader and one of his victims" ឯកសារ E152.2 ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១។

[19] ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/223.1 ទំព័រ ៧៨-៨០។

[20] ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ E1/223.1 ទំព័រ ៨៤-៨៧។

ជាច្រើនផង ក្នុងអំឡុងសវនាការលើឯកសារសំខាន់ៗ ដូច្នេះហើយ ត្រូវបានសហព្រះរាជអាជ្ញាពិចារណាថាមានសារៈសំខាន់ក្នុងការបញ្ជាក់ការពិត។ សហផលិតករមានឈុតវីដេអូរយៈពេល ១៦០ ម៉ោង និងខ្សែអាត់សំឡេងរយៈពេល ១០០០ម៉ោង ដែលមិនបានដាក់បញ្ចូលទៅក្នុងខ្សែភាពយន្ត។ ទាក់ទិនទៅនឹងព័ត៌មានដោះបន្ទុកដែលគាត់មាន គាត់ពិតជាយោងទៅលើឈុតវីដេអូ/ខ្សែអាត់សំឡេងជាច្រើនម៉ោងដែលគាត់មាននោះ។ ទោះបីជាការព្រមព្រៀងពីមុនរវាងលោក LEMKIN និង នួន ជា អាចបង្អាក់ទឹកចិត្តលោក LEMKIN មិនឱ្យផ្ដល់សម្ភារទៅឱ្យ អ.វ.ត.ក យ៉ាងណាក៏ដោយ ក៏ឥឡូវនេះជនជាប់ចោទសុខចិត្តបោះបង់ចោលកិច្ចព្រមព្រៀងនោះ។ ការបញ្ជាក់ការពិត តម្រូវឱ្យអង្គជំនុំជម្រះស្នើសុំព័ត៌មាននេះ[21]។

## ៣. ច្បាប់ជាធរមាន

10. យោងតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត នៅពេលដែលភ័ស្តុតាងនោះបំពេញផងដែរនូវបទដ្ឋាន*បឋម*នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលតម្រូវនៅក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឱ្យពិនិត្យភ័ស្តុតាង បើខ្លួនយល់ឃើញ *ក្នុងចំណោមប្រការផ្សេងទៀត* ថា មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា, មិនអាចរកបាន ក្នុងរយៈពេលសមស្របណាមួយ, ឬមិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភ័ស្តុតាង។ ជាធម្មតា ភាគីដែលស្នើសុំក៏ត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ផងដែរថា ភ័ស្តុតាងដែលបានស្នើសុំ មិនអាចរកបាននៅមុនពេលបើកសវនាការ ឬមិនអាចរកបាន ទោះបីជាមានវិរិយភាពដ៏ត្រឹមត្រូវយ៉ាងណាក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងករណីមួយចំនួន អង្គជំនុំជម្រះបានទទួលយកឯកសារដែលមិនបានបំពេញនូវលក្ខណៈវិនិច្ឆ័យនេះ រួមមាន ក្នុងកាលៈទេសៈដែលឯកសារពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងសម្ភារដែលមានរួចហើយនៅក្នុងសំណុំរឿង និងដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យប្រភពទាំងនោះត្រូវយកមកធ្វើការវាយតម្លៃជាមួយគ្នា, កាលៈទេសៈដែលឯកសារស្នើសុំនោះជាភ័ស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃដើម្បីបញ្ចៀសនូវកំហុសក្នុងការស្វែងរកយុត្តិធម៌ ឬកាលៈទេសៈដែលភាគីដទៃទៀតពុំជំទាស់ទៅនឹងឯកសារនោះ[22]។

---

[21] ប្រតិចារឹក ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៣ ទំព័រ ៨៧-៩០។

[22] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា និងសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ស្ដីពីសារទូរលេខតាមផ្លូវទូតរបស់សហរដ្ឋអាមេរិក [...] ឯកសារ E282/2 ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ៣។ ចម្លើយតបទៅនឹងសំណើតាមវិធាន៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី លោក Francois

11. អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ប្រសិនបើអង្គជំនុំជម្រះយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិផ្តួចផ្តើមឱ្យមានកិច្ចស៊ើបសួរថ្មី ដែលអាចរួមមានការស្តាប់ចម្លើយសាក្សី ឬដឹកនាំការឆែកឆេរ នៅពេលចាំបាច់[23]។ ភាពចាំបាច់នេះត្រូវតែសម្អាងលើផលប្រយោជន៍នៃយុត្តិធម៌។ ដូចគ្នាដែរ ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវបានគេយល់ដឹងបាននៅក្នុងបរិបទនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលធានានូវសិទ្ធិ របស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឱ្យបានឆាប់រហ័ស ហើយប្រធានសវនាការមានឆន្ទានុសិទ្ធិក្នុងការបដិសេធនូវរាល់នីតិវិធីដែលនាំឱ្យមានការពន្យារពេលដល់ការជំនុំជម្រះ[24]។

## ៤. សំអាងហេតុ

12. អង្គជំនុំជម្រះនឹងលើកបង្ហាញអំពីសំណើជាបីផ្នែក៖ (១) សំណើសុំឱ្យទទួលយកអ៊ីម៉ែល។ (២) សំណើសុំកោះហៅលោក LEMKIN ក្នុងនាមជាសាក្សី ឬជាអ្នកជំនាញមួយរូប និង (៣) សំណើសុំចាប់ផ្តើមបើកកិច្ចស៊ើបសួរ។

### ៤.១. ភាពអាចទទួលយកបាននៃអ៊ីម៉ែល

13. ក្រុមមេធាវីការពារក្តីស្នើសុំដាក់អ៊ីម៉ែលទៅក្នុងសំណុំរឿង។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ពេលនេះខ្លឹមសារនៃអ៊ីម៉ែលនេះទាំងមូលមាននៅក្នុងសំណុំរឿង ដោយទុកនៅកន្លែងបីដាច់ដោយឡែកពីគ្នា។ មេធាវីការពារក្តី នួន ជា បានអានអ៊ីម៉ែលនេះចូលក្នុងខ្សែអាត់ថតសម្លេង ទាំងនៅក្នុងសវនាការអសាធារណៈ ទាំងនៅក្នុងសវនាការសាធារណៈ ហើយនៅពេលនេះផងដែរ បង្ហាញថា ពាក្យពេចន៍ត្រង់នៃអ៊ីម៉ែលនេះត្រូវបានដកស្រង់នៅក្នុងសារណាដាក់ជូនអង្គជំនុំជម្រះ។ ហេតុនេះ សំណើសុំដាក់អ៊ីម៉ែលទៅក្នុងសំណុំរឿង និងដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺទុកជាឥតបានការ។ តម្លៃជាភស្តុតាងនៃអ៊ីម៉ែលនេះគឺជាបញ្ហាមួយដែលស្ថិតនៅក្នុងអំណាចឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។

### ៤.២. សំណើសុំកោះហៅលោក LEMKIN

---

Ponchaud [...] ឯកសារ E260 ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ កថាខណ្ឌ ៥។ សេចក្តីសម្រេចទាក់ទងនឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ឯកសារ E190 ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១២ កថាខណ្ឌ ១៨។

[23] *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៣៩ ។

[24] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (" ច្បាប់ អ.វ.ត.ក") មាត្រា ៣៣ថ្មី។ វិធាន ៨៥ នៃវិធានផ្ទៃក្នុង។

14. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា លោក សម្បត្តិ ដែលជាអ្នកនិយាយភាសាខ្មែរជាភាសាកំណើត និងជាបុគ្គលដែលបានដឹកនាំកិច្ចសម្ភាសន៍ទាំងឡាយជាមួយជនជាប់ចោទ នួន ជា គឺល្អបំផុតដែលត្រូវដាក់ជំនួសដើម្បីផ្តល់សេចក្តីពិស្តារស្តីពីឈុតខ្សែភាពយន្តបន្ថែម ដែលគ្មាននៅក្នុងខ្សែភាពយន្តណាមួយនៅក្នុងសំណុំរឿង។ គេហទំព័រ The *Enemies of the People* បង្ហាញថា ចម្លើយរបស់ជនជាប់ចោទ នួន ជា ត្រូវបានទទួលដោយ “ឆ្លងកាត់មួយទសវត្សរ៍នៃការងារធ្វើឡើងដោយអ្នកកាសែតម្នាក់ក្នុងចំណោមអ្នកកាសែតផ្នែកស៊ើបអង្កេតល្អជាងគេបំផុតមួយរូបរបស់ប្រទេសកម្ពុជា ឈ្មោះ ថេត សម្បត្តិ (THET Sambath)”[25]។ វាក៏បានបង្ហាញផងដែរថា លោក សម្បត្តិ បានបញ្ចុះបញ្ចូលឱ្យជនជាប់ចោទនិយាយ និងជាច្រើនដង និយាយសំដៅទៅលើការងារដែលគួរឱ្យកត់សម្គាល់របស់ លោក សម្បត្តិ[26]។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះមិនទទួលបានជោគជ័យក្នុងការព្យាយាមទាក់ទងលោក ថេត សម្បត្តិ ឡើយ[27]។

15. ផ្ទុយទៅវិញ លោក LEMKIN បានជួបលោក សម្បត្តិ នៅក្នុងឆ្នាំ ២០០៦ ហើយបានចូលរួមពាក់ព័ន្ធក្នុងខ្សែភាពយន្តទាំងអស់នេះទើបតែក្រោយពេលនោះប៉ុណ្ណោះ[28]។ លោកនិយាយភាសាខ្មែរបន្តិចបន្តួច ហើយភាគច្រើនលោកមិនបានចូលរួមនៅក្នុងកិច្ចសម្ភាសន៍ជាមួយជនជាប់ចោទនោះទេ[29]។ ស្រដៀងគ្នានេះដែរ លោក LEMKIN មិនមានសម្បទាដែលត្រូវបានកំណត់សម្រាប់គុណវុឌ្ឍិជាអ្នកជំនាញ

---

[25] អំពីខ្សែភាពយន្តនេះ “Enemies of the People” ឯកសារលេខ D344.2 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១០។

[26] អំពីខ្សែភាពយន្តនេះ “Enemies of the People” ឯកសារលេខ D344.2 ចុះថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១០។ *សូមមើលផងដែរ* លោក Ian Willoughby ជាអ្នកកាសែតមិនចេះនឿយហត់ បានដកស្រង់សក្ខីកម្មពាក់ព័ន្ធពីអតីតកម្មាភិបាលខ្មែរក្រហម នៅក្នុងខ្សែភាពយន្ត One World ដែលមានចំណងជើងថា Enemies of the People ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១០ ដែលអាចបើកមើលបានតាមរយៈ: http://www.radio.cz/en/section/curraffrs/untiring-journalist-elicits-groundbreaking-testimonies-from-ex-khmer-rouge-men-in-one-world-film-enemies-of-the-people (លោក LEMKIN បានលើកឡើងថា “ការបញ្ចេញអាថ៌កំបាំងតែមួយគត់ដែលកើតឡើងនៅក្នុងខ្សែភាពយន្តត្រូវបានរូបគាត់ (ថេត សម្បត្តិ) ជាអ្នកធ្វើតែម្នាក់ឯងគត់។ ខ្ញុំបានថតភាពយន្តជាមួយគាត់អស់រយៈពេលបីឆ្នាំចុងក្រោយនេះ។ ខ្ញុំបានធ្វើកិច្ចសម្ភាសន៍នានា និងចោទសួរសំណួរទាំងឡាយដែលយើងគ្រោងដាក់នៅក្នុងកិច្ចសម្ភាសន៍។ ប៉ុន្តែសម្រាប់រូបខ្ញុំ រឿងអាថ៌កំបាំងបំផុតជាមួយ នួន ជា [...] នេះគឺជាប្រភេទរឿងដែលមានតែលោក សម្បត្តិ ដែលជាជនជាតិខ្មែរដែលប្រជាជនទាំងនេះជឿទុកចិត្តតែម្នាក់ប៉ុណ្ណោះ ដែលអាចធ្វើបាន”)។

[27] អនុស្សរណៈធ្វើពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា “អ្នកដែលអាចជាសាក្សី-មិនអាចស្វែងរកឃើញ” ឯកសារលេខ E292/1/2 ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣។

[28] សេវាផ្សព្វផ្សាយជាសាធារណៈ, កិច្ចសម្ភាសន៍៖ Enemies of the People ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០១១។ អាចបើកមើលបានតាមរយៈ: http://www.pbs.org/pov/enemies /interview.php។

[29] ដៃគូកម្ពុជាសម្រាប់កិច្ចការសិល្បៈ, Enemies of the People - ជាខ្សែភាពយន្តរបស់លោក Rob LEMKIN ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១១។ អាចបើកមើលបានតាមរយៈ: http://www.cambodianallianceforthearts.com/enemies-of-the-people-a-film-by-rob-lemkin/។

មួយរូបនោះទេ។ ក្រុមមេធាវីការពារក្ដីបានអះអាងរួចហើយថា នេះមិនមែនជាគោលបំណងរបស់លោក LEMKIN ទេ។ ខណៈពេលដែលអង្គជំនុំជម្រះបានជូនដំណឹងអំពីចេតនារបស់ខ្លួនកាលពីមុនដល់ភាគីទាំងអស់ថាខ្លួនមិនកោះហៅលោក LEMKIN នោះទេ ក្រុមមេធាវីការពារក្ដី នួន ជា ខកខានមិនបានលើកឡើងនូវការជំទាស់ណាមួយឡើយនាពេលកន្លងមកនោះ ហើយនៅដំណាក់កាលចុងក្រោយនៃដំណើរការនីតិវិធី ក្រុមមេធាវីការពារក្ដីមិនបានផ្ដល់មូលដ្ឋានរឹងមាំដើម្បីជាបង្អែកដល់សំណើសុំរបស់ខ្លួនឡើយ[30]។

16. ឥរិយាបថរបស់លោក LEMKIN នៅក្នុងដំណាក់កាលមុនការជំនុំជម្រះបង្ហាញយ៉ាងច្បាស់លាស់នូវកង្វះនៃការផ្ដល់កិច្ចសហការ។ ទាំងរូបគាត់ ទាំងលោក សម្បត្តិ បានបញ្ជាក់ជូនដល់សមត្ថកិច្ចតុលាការ និងនៅក្នុងអត្ថបទសារព័ត៌មានផ្សេងៗជាច្រើននៅពេលនោះ ក៏ដូចជាចាប់តាំងពីពេលនោះមក អំពីហេតុផលមួយចំនួនដែលគាំទ្រដល់ការបដិសេធរបស់ពួកគាត់ ក្នុងការប្រគល់សម្ភារពាក់ព័ន្ធឱ្យដល់ អ.វ.ត.ក[31]។ នៅដំណាក់កាលចុងក្រោយនៃការជំនុំជម្រះក្ដីនេះ និងដោយគ្មានការវាយតម្លៃ

---

[30] ក្រុមមេធាវីការពារក្ដីរបស់លោក នួន ជា បានស្នើសុំឱ្យកោះហៅលោក LEMKIN ក្នុងខែ កក្កដា ឆ្នាំ ២០១១។ *សូមមើល* សំណើសុំបន្ថែមសាក្សី និងបន្តសវនាការបឋម ឯកសារ E93/9 ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ និងឧបសម្ព័ន្ធ៖ បញ្ជីសាក្សីដែលបានស្នើសុំ, ឯកសារ E93/9.1 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១។ Rob LEMKIN ពុំត្រូវបានរាប់បញ្ចូលក្នុងបញ្ជីនៃបុគ្គល ដែលនឹងត្រូវកោះហៅ ដើម្បីគាំទ្រដល់ការជំនុំជម្រះដំណាក់កាលទីមួយនេះទេ។ *សូមមើល* ឧបសម្ព័ន្ធ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី សម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២, ឯកសារ E131/1.1 ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១។ នួន ជា ពុំជំទាស់នឹងការផាត់ឈ្មោះលោក LEMKIN ចេញពីបញ្ជីនៅគ្រានោះទេ បើទោះជាភាគីត្រូវបានអញ្ជើញឱ្យដាក់ការជំទាស់ក៏ដោយ។ *សូមមើល* ការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះ ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ [...] ឯកសារ E218 ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ កថាខណ្ឌ ៣, ១១-១២។ ចុងក្រោយ មុននឹងការប្រព្រឹត្តទៅនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានផ្ដល់ការចង្អុលបង្ហាញដល់ភាគីអំពីសាក្សីនៅសេសសល់ ដែលត្រូវកោះហៅ នៅគ្រាដែលការកោះហៅលោក Rob LEMKIN ត្រូវបានបដិសេធយ៉ាងច្បាស់លាស់។ វិធីសាស្ត្រនេះត្រូវបានអនុម័ត ដើម្បីអនុញ្ញាតឱ្យភាគីលើកឡើងនូវការព្រួយបារម្ភដែលនៅសេសសល់ ពាក់ព័ន្ធនឹងសាក្សីចុងក្រោយ ដែលត្រូវកោះហៅ។ *សូមមើល* ការជូនដំណឹងអំពីសវនាការ ដែលនៅសេសសល់មុនពេលបិទកិច្ចដំណើរការនីតិវិធីសវនាការលើកស្ដុតាងនៅក្នុងសំណុំរឿង ០០២/០១ និងការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការលើកចុងក្រោយ សម្រាប់ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣, ឯកសារ E288 ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣។ នួន ជា មិនមានប្រតិកម្មចំពោះការផាត់ឈ្មោះលោក Rob LEMKIN ពីបញ្ជីនោះទេ។

[31] នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ក.ស.ច.ស បានទាក់ទងលោក Lemkin ស្នើសុំខ្សែភាពយន្តថតចម្លងមួយច្បាប់ គឺខ្សែភាពយន្ត *Enemies of the People* មុនថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១០។ *សូមមើល* លិខិតផ្ញើពីការិយាល័យសហចៅក្រមស៊ើបអង្កេតជូនលោក Rob Lemkin ឯកសារលេខ D344/1.1 ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១០។ លោក Lemkin បានឆ្លើយតបនៅថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០ ដោយបង្ហាញថា លោកនឹងមិនប្រគល់ខ្សែភាពយន្តឱ្យអង្គជំនុំជម្រះទេ ប៉ុន្តែ នឹងមានបំណងរៀបចំចាក់ផ្សាយខ្សែភាពយន្តជាសាធារណៈនៅក្នុងទីក្រុងភ្នំពេញ។ *សូមមើល* សារអេឡិចត្រូនិកផ្ញើពីលោក Robert LEMKIN ជូនសហចៅក្រមស៊ើបអង្កេត

លើការផ្តល់ហេតុផលដែលត្រូវបានលើកឡើងទាំងអស់នេះ អង្គជំនុំជម្រះមិនមានការជឿជាក់លើតម្លៃនៃការកោះហៅសាក្សីដែល *តាមហេតុការណ៍ពិត* បានបង្ហាញជានិច្ចនូវភាពស្ទាក់ស្ទើរក្នុងការជួយដល់តុលាការ។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា សក្ខីកម្មរបស់លោក LEMKIN នឹងមិនជួយដល់អង្គជំនុំជម្រះនៅក្នុងការស្វែងរកការពិតនោះទេ។ ប្រភពភ័ស្តុតាងដែលលោក LEMKIN និងលោក សម្បត្តិ អាចមាននោះ នឹងជួយជាប្រយោជន៍បានច្រើនជាងសក្ខីកម្មរបស់ពួកគាត់។

## ៤.៣ <u>សំណើសុំបំពេញកិច្ចស៊ើបសួរ</u>

17. នៅក្នុងអ៊ីម៉ែលនោះមានការអះអាងពីរធំៗ។ អង្គជំនុំជម្រះមិនមានការព្រួយបារម្ភ ដោយសារការអះអាងដែលថា ចម្លើយរបស់ នួន ជា នៅក្នុងខ្សែភាពយន្តមិនត្រូវបានបកស្រាយបានត្រឹមត្រូវនោះទេ។ ចម្លើយរបស់ នួន ជា នៅក្នុងខ្សែភាពយន្តនោះ មានអត្ថន័យច្បាស់លាស់ទៅហើយ និងនៅក្នុងករណី

---

ឯកសារលេខ D344/1.2 ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១០។ សហចៅក្រមស៊ើបអង្កេតបានឆ្លើយតបទៅលោក LEMKIN ថា ដើម្បីបញ្ជាក់ឱ្យច្បាស់អំពីតម្លៃជាភ័ស្តុតាងដែលអាចមាននៃខ្សែភាពយន្ត អង្គជំនុំជម្រះនឹងត្រូវការពិនិត្យមើលខ្សែភាពយន្ត និងមានជម្រើសដាក់វាចូលក្នុងសំណុំរឿង មិនមែនគ្រាន់តែទស្សនាខ្សែភាពយន្តនោះនៅទីសាធារណៈនោះទេ។ *សូមមើល* លិខិតឆ្លើយតបរបស់សហចៅក្រមស៊ើបអង្កេតផ្ញើជូនលោក Robert LEMKIN ឯកសារលេខ D344/1.3 ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១០។ សហចៅក្រមស៊ើបអង្កេតក៏បានកត់សម្គាល់ផងដែរថា លោក LEMKIN បាននិយាយប្រាប់ភ្នាក់ងារសារព័ត៌មានបារាំងកាលពីថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១០ ថា "ខ្សែភាព យន្តនឹងត្រូវបានតុលាការយកប្រើប្រាស់ ហើយនឹងត្រូវផ្តល់ឱ្យតុលាការ។ យើងមានមោទនភាពអំពីខ្សែភាពយន្តនេះខ្លាំងណាស់"។ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ការពន្យារពេលណាមួយក្នុងការផ្តល់ភ័ស្តុតាងនេះឱ្យតុលាការនឹងធ្វើឱ្យភ័ស្តុតាងនេះមិនត្រូវបាន អ.វ.ត.ក ធ្វើការពិចារណា។ *សូមមើល* ឯកសាលេខ D344/1.3. លោក LEMKIN មិនបានឆ្លើយតបទៅនឹងសំណើសុំនេះទេ ហើយ ក.ស.ច.ស បានចាប់ផ្តើមទូរស័ព្ទទាក់ទងនៅក្នុងខែ មីនា ឆ្នាំ ២០១០ ដែលក្នុងនោះលោក LEMKIN បានលើកឡើងម្តងទៀតថា លោកមិនបានត្រៀមផ្តល់ខ្សែភាពយន្តថតចម្លងទៅតុលាការមុនកាលបរិច្ឆេទ ចាក់ផ្សាយជាសាធារណៈនោះទេ។ *សូមមើល* ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងខ្សែភាពយន្ត *Enemies of the People* ឯកសារលេខ D344/1 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១០។ រហូតទល់នឹងថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២ ដែលមានរយៈពេលពីរឆ្នាំក្រោយមកទៀត ដែលខ្សែភាពយន្ត *Enemies of the People* និង *One Day at Po Chrey* ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង ក្រោយពេលដែលការិយាល័យសហព្រះរាជអាជ្ញាបានទិញខ្សែភាពយន្តនេះពីទីផ្សារមក និងបានដាក់ជូនទៅអង្គជំនុំជម្រះ។ *សូមមើល* ខ្សែអាត់ថតវីដេអូ៖ *Enemies of the People* ឯកសារលេខ E186.1R ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២។ ខ្សែអាត់ថតវីដេអូ៖ *One Day at Po Chrey* ឯកសារលេខ E186.1R ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០១២។ លោក LEMKIN មិនបានផ្តល់ខ្សែភាពយន្តណាមួយជូនដល់តុលាការដូចដែលគាត់បានសន្យាឡើយ។ ទោះបីជាលោកបានដឹងយ៉ាងច្បាស់អស់រយៈពេលបីឆ្នាំចុងក្រោយនេះហើយថា អ.វ.ត.ក កំពុងពិចារណាអំពីការទទួលខុសត្រូវរបស់ នួន ជា ហើយនឹងពិនិត្យមើលខ្សែភាពយន្ត *Enemies of the State* (ដែលបញ្ចូលនៅលើខ្សែភាពយន្តឈុតឌីវីឌីតែមួយនឹងខ្សែភាពយន្ត *One day at Po Chrey*) ក៏ដោយ ក៏គាត់បានសម្រេចចិត្តមិនជូនដំណឹងដល់អង្គជំនុំជម្រះអំពីអត្ថិភាពនៃព័ត៌មានដោះបន្ទុកដែលបានលើកឡើងនេះ ដោយលោកបានសម្រេចចិត្តដកចេញពីខ្សែភាពយន្តរបស់ខ្លួន រហូតដល់ពេលមុនបន្តិចនៃដំណាក់កាលបិទបញ្ចប់ការបង្ហាញភ័ស្តុតាង។

មិនច្បាស់លាស់ ចម្លើយទាំងនោះនឹងត្រូវបានត្រួតពិនិត្យយ៉ាងល្អិតល្អន់ជាភាសាដើមនៃចម្លើយទាំងនោះ ដោយអ្នកនិយាយភាសាខ្មែរជាភាសាកំណើត។ ហេតុនេះ ការជួយរបស់លោក LEMKIN នៅក្នុងការបកស្រាយចម្លើយទាំងអស់នេះ នឹងមិនជួយដល់អង្គជំនុំជម្រះឡើយ។

18. ការអះអាងទីពីរនៅក្នុងអ៊ីម៉ែលនោះ មានលក្ខណៈទូលំទូលាយខ្លាំងជាង ទោះបីជាខ្វះសេចក្តីពិស្តារក៏ដោយ។ មានការអះអាងថា លោក LEMKIN មានបណ្តុំនៃភ័ស្តុតាង ដ៏មានតម្លៃជាច្រើនដែលដោះបន្ទុកជនជាប់ចោទ នួន ជា ជាពិសេសសម្រាប់ព្រឹត្តិការណ៍ទាំង ឡាយនៅទួលពោធិ៍ជ្រៃ។ ក្រុមមេធាវីការពារក្តី នួន ជា បញ្ជាក់ថា ខ្សែភាពយន្តនោះផ្ទាល់ ពុំមានភ័ស្តុតាងដោះបន្ទុកដែលត្រូវបានសរសេរឱ្យដឹងនៅក្នុងអ៊ីម៉ែលនោះទេ ប៉ុន្តែមេធាវីការពារក្តីអះអាងថា អាចមានព័ត៌មានដោះបន្ទុកនៅក្នុងឈុតភាពយន្តដែលថតដោយលោក LEMKIN និងលោក សម្បត្តិ ដែលមិនទាន់បានបញ្ចេញដល់សាធារណជននៅឡើយ។

19. ជាបញ្ហាបឋមពាក់ព័ន្ធនឹងរឿងនេះ អង្គជំនុំជម្រះដឹងអំពីកាតព្វកិច្ចរបស់ខ្លួនក្នុងការធ្វើឱ្យមានតុល្យភាពរវាងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី ជាមួយនឹងការជំនុំជម្រះក្តីឆាប់រហ័ស[32]។ ដើម្បីសម្រេចបានតុល្យភាពនេះ តម្លៃដែលអាចមាននៃការទទួលយកភ័ស្តុតាងត្រូវបានយកមកពិចារណា ទល់នឹងក្តីកង្វល់ពាក់ព័ន្ធនឹងការពន្យារពេលសវនាការដោយមិនត្រឹមត្រូវ។ ដោយចងចាំជានិច្ចនូវកាតព្វកិច្ចដ៏មានសារៈសំខាន់នេះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់នូវក្តីកង្វល់មួយចំនួន ក្នុងការបើកកិច្ចស៊ើបសួរទៅលើអត្ថិភាពនៃសម្ភារដែលបានលើកឡើង។

---

[32] មាត្រា៣៣ ថ្មី នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ("សាលាដំបូង [នៃអ.វ.ត.ក] ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័សតាមនីតិវិធីជាធរមាន...")។ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ឯកសារ E163/5/1/13 ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ កថាខណ្ឌ៥១ ("ដោយដឹងថា អាយុកាន់តែចាស់ និងសុខភាពរបស់ជនជាប់ចោទកាន់តែធ្លាក់ចុះ ក៏ដូចជា ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មានសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចនេះ ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃ ដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទ ដែលសេសសល់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delalic និងជនដទៃទៀត* សាលក្រមរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY (IT-96-21-A) ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ២៩០ ("ដំណាក់កាលនៃការជំនុំជម្រះ ដែលភស្តុតាងត្រូវបានស្នើសុំឱ្យទទួលយក និងដំណើរយឺតយ៉ាវជាសក្តានុពល ដែលនឹងបណ្តាលឱ្យកើតមានចំពោះការជំនុំជម្រះ គឺជាបញ្ហាដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងយុត្តិធម៌ដល់ជនជាប់ចោទ បើនិយាយអំពីការទទួលយកភស្តុតាងថ្មីៗ [...]")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Aleksovski*, សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាស្តីពីការទទួលយកភស្តុតាង, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY (IT-95-14/1-AR73) ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ កថាខណ្ឌ ១៩ ("គោលបំណងនៃវិធាន គឺដើម្បីលើកកម្ពស់ការជំនុំជម្រះដ៏យុត្តិធម៌ និងឆាប់រហ័ស ហើយអង្គជំនុំជម្រះសាលាដំបូងត្រូវមានភាពបត់បែន ដើម្បីសម្រេចគោលដៅនេះឱ្យបាន")។

20. ជាដំបូង ផ្អែកតាមព័ត៌មានដែលបានផ្តល់ឱ្យដោយក្រុមមេធាវីការពារក្តី នួន ជា វាទំនងជាថា សម្ភារដែលលោក LEMKIN មាន ពិតជាមិនមែនជាសម្ភារថ្មីនោះទេ ពីព្រោះផ្នែកសំខាន់នៃឈុតសម្ភាសន៍របស់លោក នួន ជា ត្រូវបានថតជាភាពយន្តមុន ខែ ឧសភា ឆ្នាំ ២០០៩[33]។ ហេតុដូច្នេះ មានសំណួរមួយពាក់ព័ន្ធនឹងបញ្ហាថាតើសម្ភារបែបនេះនឹងអាចទទួលយកបានដែរឬទេ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង។

21. ទីពីរ ក្រុមមេធាវីការពារក្តី នួន ជា បានបង្ហាញកាលពីមុនថា លោក LEMKIN បានអះអាងអំពីបុព្វសិទ្ធិសារព័ត៌មាននៅក្នុងការបដិសេធមិនផ្តល់សម្ភារដែលខ្លួនមានជូនដល់ អ.វ.ត.ក[34]។ អ៊ីម៉ែលដែលបានលើកឡើងមិនផ្តល់នូវការបង្ហាញជាវិជ្ជមានថា លោក LEMKIN មានផ្លាស់ប្តូរគោលជំហររបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះទេ។ ដោយពិចារណាលើការបង្ហាញអំពីការមិនសហការរបស់លោក LEMKIN ក្នុងការស៊ើបអង្កេតលើបទចោទនានាដែលចោទជាបញ្ហានៅពេលនេះ[35] អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានគ្រប់គ្រាន់ក្នុងការបើកជាថ្មីឡើងវិញ នូវបែបបទនៃកិច្ចស៊ើបសួរដែលបានអនុវត្តយ៉ាងជិតដល់កាលពីមុននោះឡើយ។

22. ទីបី ជនជាប់ចោទ នួន ជា លើកឡើងថា ពេលនេះ គាត់ត្រៀមខ្លួនរួចហើយក្នុងការអភ័យទោសឱ្យសហផលិតករខ្មែរភាពយន្តដែលបានសន្យារក្សាការសម្ងាត់នៃកិច្ចសម្ភាសន៍របស់គាត់។ ទោះបីជាក្រុមមេធាវីការពារក្តីបានដឹងអំពីការអះអាងនូវបុព្វសិទ្ធិសារព័ត៌មាន យ៉ាងហោចណាស់តាំងពី ខែ មិថុនា ឆ្នាំ ២០១១ មកម្ល៉េះ នៅពេលដែលក្រុមមេធាវីការពារក្តីបានជូនដំណឹងដល់អង្គជំនុំជម្រះអំពីព័ត៌មាននេះយ៉ាងណាក៏ដោយ ក៏ នួន ជា បានពន្យារពេលជិតពីរឆ្នាំហើយ មុនពេលបដិសេធចោលនូវការសន្យារក្សាការសម្ងាត់នេះ។ ហេតុនេះ សេចក្តីសម្រេចផ្ទាល់ខ្លួនរបស់គាត់បានបង្អាក់តុលាការមិនឱ្យទទួលបានសម្ភារដែលបានលើកឡើងនេះឱ្យបានទាន់ពេលវេលានោះឡើយ។

23. ទីបួន នេះជាលើកទីមួយដែលអង្គជំនុំជម្រះបានស្តាប់ឮពីក្រុមមេធាវីការពារក្តី នួន ជា ថា ព័ត៌មានដោះបន្ទុកអាចត្រូវបានថតសម្លេងទុកដោយលោក LEMKIN។ ប្រសិនបើព័ត៌មានដោះបន្ទុកនេះអាចមានប្រភពចេញមកពីកិច្ចសម្ភាសន៍ជាមួយ នួន ជា អង្គជំនុំជម្រះអាចនឹងរំពឹងថា ព័ត៌មាននេះនឹងត្រូវ

---

[33] Real Screen, សំណួរ និងចម្លើយ៖ 'សត្រូវរបស់ប្រជាជន' អ្នកដឹកនាំរឿង Rob LEMKIN, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១១ ដែលអាចមើលបាននៅ http://realscreen.com/2011/01/05/enemies-20110105/

[34] ឧបសម្ព័ន្ធ៣៖ ការរៀបចំសម្ភារសម្រាប់ដំណើរការជំនុំជម្រះ – បញ្ជីបឋម៖ សេចក្តីសង្ខេបព័ត៌មានរបស់សាក្សី – ក្រុមមេធាវីការពារក្តីរបស់លោក នួន ជា, ឯកសារ E93/4.3 ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៧៤ (ភាសាអង់គ្លេស)។ ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះសាក្សីដែលស្នើ (ដោយ នួន ជា), ឯកសារ E93/9.1 ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០១១ A-24, A-25។

[35] *សូមមើល* ជើងទំព័រ ៣១ ខាងលើ។

បានដាក់ជូនអង្គជំនុំជម្រះមុនដំណាក់កាលនាទីចុងក្រោយនេះ។ ដោយពិចារណាលើចំណុចនេះ ក៏ដូចជាកង្វះព័ត៌មានលម្អិតទាំងស្រុងពាក់ព័ន្ធនឹងព័ត៌មានដោះបន្ទុក ដែលលោក LEMKIN មាននោះ សំណើសុំបំពេញកិច្ចស៊ើបសួរនេះ គឺគ្រាន់តែជា "ការស្វែងរកព័ត៌មានដែលពុំមានមូលដ្ឋានច្បាស់លាស់" ប៉ុណ្ណោះ ដែលផ្ទុយគ្នាដោយផ្ទាល់ទៅនឹងកាតព្វកិច្ចរបស់អង្គជំនុំជម្រះក្នុងការដឹកនាំការជំនុំជម្រះក្តីឱ្យបានឆាប់រហ័ស[36]។

24. ជាចុងក្រោយ ដោយពិចារណាអំពីសុខភាពទន់ខ្សោយរបស់ជនជាប់ចោទ និងភាពមិនប្រាកដប្រជាផ្សេងៗទៀតដែលអាចរាំងស្ទះដល់ការចេញសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ឱ្យបានទាន់ពេលវេលា មានក្តីកង្វល់មួយថា ប្រសិនបើអង្គជំនុំជម្រះបើកឱ្យមានកិច្ចស៊ើបសួរមួយ នោះកិច្ចនេះនឹងមិនអាចបញ្ចប់នៅក្នុងអំឡុងពេលសមស្របបានទេ។ បើទោះបីជាលោក LEMKIN ធ្វើការឆ្លើយតបគួរជាទីពេញចិត្តទៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរក៏ដោយ ក៏ព័ត៌មាននេះនឹងមិនអាចដាក់ចូលទៅក្នុងសំណុំរឿង និងដាក់ជូនអង្គជំនុំជម្រះឱ្យបាននៅក្នុង អំឡុងពេលសមស្របបានឡើយ។ ផ្អែកលើកិច្ចសម្ភាសន៍របស់សារព័ត៌មានជាមួយលោក LEMKIN វាទំនងជាថា មានខ្សែអាត់ថតវីដេអូដែលមានរយៈពេល ១៦០ម៉ោង និងខ្សែអាត់ថតសម្លេង ដែលមានរយៈពេល ១០០០ម៉ោង ដែលលោក LEMKIN និងលោក សម្បត្តិ បានរក្សាទុក។ ហេតុនេះ ភាគីនានានឹងត្រូវការពេលវេលាជាច្រើន ដើម្បីពិនិត្យមើលឡើងវិញនូវខ្សែអាត់ ទាំងនោះដើម្បីកំណត់ព័ត៌មានពាក់ព័ន្ធដែលអាចមាន។ បន្ទាប់មកទៀត មុនពេលដាក់ឯកសារណាមួយនៅចំពោះមុខអង្គជំនុំជម្រះ វាគួរតែត្រូវបានបកប្រែទៅជាបីភាសាជាផ្លូវការរបស់តុលាការនេះ។ ដោយសារតែលោក សម្បត្តិ បានដឹកនាំកិច្ចសម្ភាសន៍ ដូច្នេះ

---

[36] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Galic,* សេចក្តីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្តីពាក់ព័ន្ធនឹងភស្តុតាងថ្មីៗ, អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់តុលាការ ICTY (IT-98-29-A) ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៦ (*រកឃើញថា* ញត្តិដែលដាក់នៅដំណាក់កាលដ៏យឺតយ៉ាវបំផុតនៃកិច្ចដំណើរការនីតិវិធីចាំបាច់ត្រូវបានគាំទ្រដោយមូលហេតុត្រឹមត្រូវ និងដោយគ្មានការកំណត់លក្ខខណ្ឌជាក់លាក់ណាមួយនោះ គឺប្រៀបបានទៅនឹងការស្ទូចត្រីកម្សាន្តមួយ)។ សូមមើលផងដែរ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Delalic,* សេចក្តីសម្រេចលើសំណើជាជម្រើសផ្សេងរបស់រដ្ឋអាជ្ញា ដើម្បីពិនិត្យឡើងវិញនូវរឿងក្តីរបស់រដ្ឋអាជ្ញា, អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTY, ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៣៤ (ដើម្បីទទួលយកភស្តុតាងជាលក្ខណៈតាមកាលៈទេសៈ ដែលបានដាក់នៅដំណាក់កាលដ៏យឺតបំផុតនៃដំណើរការនីតិវិធី ទោះត្រូវបានអនុញ្ញាតចាប់តាំងពីដំណាក់កាលដំបូងៗ "ភាពអយុត្តិធម៌នៃការបដិសេធភស្តុតាងនេះ គួរតែហួសពីការអត់ធ្មត់")។ ករណីរឿងក្តី *រដ្ឋអាជ្ញា* ទល់នឹង *Kanyabashi,* សេចក្តីសម្រេចលើញត្តិរបស់ Kanyabashi ស្នើសុំបើកឡើងវិញសំណុំរឿងរបស់គាត់ និងដើម្បីរំលឹកឡើងវិញនូវសំណួរ ចម្លើយសាក្សីរបស់រដ្ឋអាជ្ញា, អង្គជំនុំជម្រះសាលាដំបូង ICTR (ICTR-96-15-T), ចុះថ្ងៃទី ០២ កក្កដា ២០០៨ កថាខណ្ឌ ២៣-២៥ (សម្រេចថា តម្លៃជាភស្តុតាងនៃភស្តុតាងថ្មីចាំបាច់ត្រូវតែមានទម្ងន់ធ្ងន់ជាងព្យសនកម្ម ដែលបណ្តាលមកពីការពន្យារពេលកិច្ចដំណើរការនីតិវិធីប្រកបដោយភាពយុត្តិធម៌ និងឆាប់រហ័ស ហើយដែលថា កត្តាពាក់ព័ន្ធដែលត្រូវពិចារណា រួមមាន ដំណាក់កាលវិវត្តន៍ជាច្រើនមកហើយនៃការជំនុំជម្រះក្តី និងភាពដែលអាចពន្យារពេលថែមទៀត)។

កិច្ចសម្ភាសន៍ទាំងនោះទំនងជាបានធ្វើឡើងតែជាភាសាខ្មែរតែមួយប៉ុណ្ណោះ ហើយការបកប្រែកិច្ចសម្ភាសន៍ទាំងអស់នេះក៏នឹងត្រូវចំណាយពេលវេលាជាច្រើនផងដែរ។

**ហេតុដូច្នេះ អង្គជំនុំជម្រះ÷**

**សម្រេច** ទុកជាមោឃៈសំណើសុំដាក់អ៊ីម៉ែលនេះនៅចំពោះមុខអង្គជំនុំជម្រះ ។

**បដិសេធ** សំណើសុំកោះហៅលោក Rob LEMKIN ក្នុងនាមជាសាក្សី ឬអ្នកជំនាញ។ និង

**បដិសេធ** សំណើសុំចាប់ផ្ដើមបើកកិច្ចស៊ើបសួរ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង។

**រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៣**

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**